DATA FOR THE STUDY OF LANGUAGES OF ASIA AND AFRICA 4

# AUSTRO-ASIATIC SERIES

## KHMER (2)

## CBAP SREI

(Edition of Institut Bouddhique, 1862)

Edited by

Y. SAKAMOTO

Institute for the Study of Languages and Cultures of Asia and Africa

Tokyo University of Foreign Studies

1989

DATA FOR THE STUDY OF LANGUAGES OF ASIA AND AFRICA 4

# AUSTRO-ASIATIC SERIES

## KHMER (2)

## CBAP SREI

(Edition of Institut Bouddhique, 1862)

Edited by

Y. SAKAMOTO

Institute for the Study of Languages and Cultures of Asia and Africa

Tokyo University of Foreign Studies

1989

( TEXT )

00101 ច្បាប់ស្រី

00102 បទកាកគតិ

00103 អហំ នាម-រាជចូឡំ បុត្តោ វិញ្ញោ កម្ពុជនគរេ ទេស្សេ អត្តោ អាចរិយោ បរិបឋិតា ។

00104 អន្តអញរាជបុត្រ ក្នុងរាជ្យបរិសុទ្ធ ក្រុងកម្ពុជា នាមអនុជនាថ ចូឡជាតិក្សត្រា យល់នូវអត្ថា អាចារ្យថែងទុក ។

00105 និកាយបាលិ ព្រះអសីតិនិបាតជាតក សំដែងលក្ខណា ស្រីមាយាអាក្រក់ ចើកអាសលាមក បន្អិនមាក់ងាយ ។

00106 សំដែងលក្ខណា ស្រីមានកិរិយា សុចរិតកបកាយ ឲ្យអស់ប្រុសស្រី លោកិយទាំងឡាយ ដឹងដោយបរិយាយ មាយាស្រ្តី ។

00107 ឯអន្តអញឯង គន់គិតចារថែង ពីព្រះបាលី ជាពាក្យកាព្យា ពណ៌នាសេចក្តី ចងជាច្បាប់ស្រី ទុកតាមអត្ថ ។

00108 ពុទ្ធសាសនា អតិក្កន្តា អសីតិគេ សតាធិក ទ្វេសហស្សេ មហាសករាជ ឯកសប្តបញ្ចទ្វេ ។

00109 ចុល្លសករាជទៅ ពាន់មួយរយកៅសិបប្រាំបួនគ្រប់ ថ្ងៃសៅរ៍ទៀនទេ នាខែបុស្សដប់ វេលាចរិះឯយប់ យាមមួយសេសម៉ោង ។

00201 រៀបរៀងសេចក្តី ជាបទកាកគតី ដំណាលទំនង ស្រីជួស្រីជា តាមបាលីចង ទុកជាគន្លង ក្បួនច្បាប់តទៅ ។

00202 ត្រាន់មើលត្រាន់មាន ចិត្តចាំប្រៀនប្រាណ កុំឲ្យអាស្រូវ កុំត្រាប់មាយា ទុកជាធ្វើត្រូវ កុំត្រាប់ចើកចូវ ទុកជាស្មោះស្មាន ។

00203 កុំត្រាប់ស្រីអាស គិតថាដ្បិតខ្លាស អៀនរីងអស់ប្រាណ កុំត្រាប់បន្អិន ថាមិនសាមាន្យ កុំត្រាប់សន្តាន មាក់ងាយស្វាមី ។

00204 គិតថាគួរទេ មិនគួរស្និទ្ធស្នេហ៍ រាប់រកជាប្តី មារយាទទាំងប្រាំ ចូរចាំគ្រប់ស្រី សុទ្ធសឹងអប្រិយ គ្មានល្អមួយឡើយ ។

00205 គួរត្រាប់គួរគ្រង គួរចាំគួរចង គួរកុំកន្តើយ មារយាទសុចរិត ល្អពិតជាត្រើយ ស្រីណាត្រាប់ហើយ ហៅប្រសើរស្រី ។

00206 គួរមើលឲ្យច្បាស់ គួរចាំឲ្យណាស់ តាមដោយវិធី អាចារ្យថែងចង ក្រមងសេចក្តី ក្នុងព្រះបាលី និកាយសុត្តា ។

00207 នេះនិទានសំដែង បរិយាយចារចែង ដើមបទអដ្ឋាលិឋាទេហិ សុចរិតា ឥត្ថីលក្ខណា មន្តលច្ចេះពិត ។
00208 ប្រែថាស្រីជា កើតគបលក្ខណា ដោយនូវសុចរិត មន្តលប្រាំបី ឲ្យស្រីពិនិត្យ ចាំយកជាក្រិត្យ គ្រប់រូបស្ត្រី៖
00209 ១ដើមបទពណ៌នា លោកថាស្រីជា សុចរិតភក្តី បុករាបស្រគត់ ផ្គន់ផ្គត់សំដី ការកេរ្ត៍ខ្មាសស្រី បរិសុទ្ធមែនមួន ។
00301 ២លោកថាស្រីត្រន់ កាន់សុចរិតផ្គន់ គំនិតចេះស្ងួន អស់ទ្រព្យសម្បត្តិ ប្រយ័ត្នថែធួន ទុកដាក់ខ្ជាប់ខ្ជួន មិនមានប្រមាទ ។
00302 ៣លោកថាស្រីតាប់ កាន់សុចរិតខ្ជាប់ ឧស្សាហ៍សង្វាត ធ្វើការសន្សំ គៀនខំឲ្យឃ្លាត ឲ្យទ្ធិឧហាត មិនមានស្ទៀមដៃ ។
00303 ៤លោកថាស្រីប្រាជ្ញ សុចរិតអន់អាច ចេះអធ្យាស្រ័យ ញាតិព្រៀនទៅមក រាប់រករួសវៃ ទោះជនដទៃ ក៏រាប់តាមពិត ។
00304 ៥លោកថាស្រីស្អាត សុចរិតគ្មានឃ្លាត មែនមានគំនិត ចេះរៀបអាហារ ភ្នាក់ងារស្រីពិត រណ្តាប់ផ្តាប់ចិត្ត ប្តីគ្រប់វេលា ។
00305 ៦លោកថាស្រីស្មោះ កាន់សុចរិតឆ្មោះ ចាំចិត្តស្នេហា តែនឹងអន្តប្តី ឥតបីវេរា ស្ម័គ្រស្មោះស្មើជា និត្យនៅរៀបរៀន ។
00306 ៧លោកថាស្រីស្លូត សុចរិតរហូត អបអត់ឥតល្អៀន តាមពាក្យប្តីផ្តាំ ចងចាំទុកទៀន ពោលពាក្យមិនឃ្លៀន មិនឃ្លាតសត្យា ។
00307 ៨លោកថាស្រីស្មើ សុចរិតសរពើ អាចរង់ផានា ទម្ងន់ចិត្តប្តី ទោះបីទុក្ខា ឬត្រកម្តេចម្តា អាចទទួលប្រាណ ។
00308 សុចរិតប្រាំបី ជាមង្គលស្រី ប្រសើរក្រមាន អ្វីមកផ្ទឹមផ្ទាល់ ឲ្យដល់នេះបាន ស្រីណាអាចធ្យាន ចិត្តចាំរៀនយក៍ ។
00309 ទាំងប្រាំបីច្បាប់ ហៅស្រីមហាតាប់ លោកិយកម្រ ស្រីកាន់សុចរិត ប្រព្រឹត្តល្អិតល្អ ស្រីណាថាក្រ ធ្វើតាមពុំបាន ។
00401 លោកថាស្រីនោះ ចិត្តអាក្រក់ស្មោះ ស្អប់ដំបូន្មាន ផ្សាដោយសារចិត្ត ទុច្ចរិតសន្តាន បង្ហិនធនធាន ចេកអាសមាយា ។

00402 គិតដូច្រើនកល ក្រដឹងចេះដល់ លែបខាយពុតវា បើចិត្តចង់ស្រាប់ ចង់ស្លាប់ហាក់ជា ងាយដាយសោះសា ចេះឯងដឹង
ឯង ។

00403 ឯត្រង់ច្បាប់ល្អ គិតទេយល់ក្រ កម្រក្រលែង ក្រព្រោះមិនចង់ ប្រឹងអង្គឲ្យស្ដែង ក្រដោយចិត្តល្បែង ចំណង់តណ្ហា ។

00404 អំពើសុចរិត អធ្យាស្រ័យចិត្ត សំអាតឧស្សាហ៍ ស្មោះស្មោះសុតត្រង់ ផ្គត់ផ្គង់កិត្យា ប្រាំបីនេះណា សុចរិតប្រាកដ ។

00405 ឯសុចរិតស្រី ផ្គត់ផ្គង់ស្វាមី លោកឲ្យអបអត់ ខនអៀនចិត្តទុំ ចេះគន់បែបបទ តាមតែប្ដីពត់ ម្ដេចៗតាមបាន ។

00406 មិនមានប្រកែក មិនមានជជែក ថាធ្វើមិនបាន ទោះអៀនអន់អត់ សង្កត់ចិត្តប្រាណ តាមចិត្តប្ដីធ្យាន ម្ដេចៗមិនថា ។

00407 ច្បាប់នេះគួរស្រី នៅនាលោកិយ ផ្ចង់ចិត្តឧស្សាហ៍ កាន់គិសុចរិត ជាក្រឹត្យថ្លៃថ្លា ឲ្យធ្លាប់ជាក់ជា ចរិតសព្វថ្ងៃ ។

00408 កាន់បានដូច្នោះ នឹងពុកេរ្ដិ៍ឈ្មោះ ប្រសើរពេកក្រៃ នឹងបានសាន្តសុខ ចៀសទុក្ខចង្រៃ ដល់បរលោកថ្ងៃ សោយ
សុខសួគ៌សិទ្ធ ។

00409 សំដែងសេចក្ដី ពីមង្គលស្រី ប្រសើរពេកពិត គ្រប់ទាំងប្រាំបី ក្រឹត្យស្រីសុចរិត ចែងចប់ភាសិត តាមព្រះបាលី ។

00410 គម្ពីរនិកាយ សំដែងអធិប្បាយ មង្គលស្ត្រី នេះនឹងតតែង សំដែងអំពី អសីតិនិបាតជាតកេ ។

00501 ឥទំសគ្គា កុណាលទហា ហិមវន្តេ អនភិរតបីឡិតេ បញ្ចសតេ ភិក្ខុកថេសិ ។

00502 រីព្រះសព្វញ្ញូ ព្រះអង្គជាគ្រូ គ្រប់មនុស្សប្រុសស្រី នឹងទេពនិកាយ ដូចនាយសារថី ទូន្មានពាជី ដោយដូចចិន្តា ។

00503 ព្រះអង្គគង់ឮ កុណាលស្រស់ស្រី ទៀបព្រៃហិមវា ប្រារព្ធនឹងអង្គ ភិក្ខុវង្សសក្យា រាជប្រាំរយជា កំលោះគ្រប់អង្គ ។

00504 សុទ្ធសឹងមានចិត្ត ស្រើបស្រាលគន់គិត ដល់គ្តីចំណង់ រសាប់រសាយ ពុំស្ងាយសីលសង្ឃ គន់គិតកួចចង់ សឹកសេពមាតុ
គ្រាម ។

00505 ទ្រង់ជ្រាបហើយត្រាស់ ទេសនាច្បាប់ច្បាស់ កុំឲ្យរវីមរវាម ចិត្តចង់តាមស្រើប កម្រើបដោយកាមគុណទាក់ទាម មន្ទិល
សិក្ខា ។

00506 ឲ្យភិក្ខុផង ដឹងដោយទំនង ដំណើរមាយា ស្រីទាំងសែសិប បូករាប់ស្រីណា បង្ហិនទ្រព្យា នោះដប់ចរិត ។

00507 ស្រីចិត្តចោកសព្វ ប្រាំបីដណ្ដប់ ស្រីអាសខូចចិត្ត មានដល់ម្ភៃ ឯស្រីតែងគិត មាក់ងាយប្ដីពិត ដប់ពីរកិរិយា ។

00508 អំពើទុច្ចរិត ទាំងប្រាំគំនិត ប្រមូលផ្តុំគ្នា ត្រូវមួយរយគត់ តាមបទព្រះបាលីលោកទេសនា ក្នុងព្រះគាថ ។

00509 ចត្តាឡីសាយឋានេហិ ឥត្ថិសាមិកំ អច្ចាវទន្តំ ប្រែបាលីយ៉ ស្រីមាយាលោកតាំង សែសិបគំនិត៖

00510 ១នេះដើមស្រីមាយា អៀនតែប្តីវា ពុំព្រមតាមចិត្ត ប្តីផ្តាំដូចម្តេច អៀនគេចមិនស្សិត ឯស្រីសុចរិត គ្មានអៀននឹងប្តី ។

00601 ២ស្រីមាយាឥតល្ហៃ ចូលដេកច្រើនប្រែ ខ្នងឲ្យស្វាមី ហាក់ជិនហាក់ណាយ ចង់ផាយរកថ្មី មោះប្រុសចក្តី ចង់រួមរសប្រាណ ។

00602 ៣ស្រីមាយាលាយចើក ប្តីលក់លួចបើក ទ្វារលបចេញបាន ទៅរកគេឯង ប្រឡែងសើចសាន ហើយវិលមកថ្កាន ដេកធ្វើព្រងើយ ។

00603 ៤ស្រីមាយាឥតលក្ខណ៍ ប្តីគងប្តីគាក់ ប្តីពាល់ខ្លួនហើយ គេចទាត់គេចទះ ប្រមះគោះគើយ ធ្វើហាក់ធ្វើហើយ មិនមានចំណង់ ។

00604 ៥ស្រីមាយាអប្រិយ ប្តីរួមវេណី ប្រកែករារង់ ដន្ទឹមធំតូច ហាក់ដូចមិនចង់ ព្រោះអាក់អៀនអន្ត មោះចង់ស្នេហា ។

00605 ៦ស្រីមាយារួសរេ ប្តីនឹងរួមវេណីប្រែពោលថា ឈឺក្បាលឈឺពោះ គឺមោះវាជា វាទាស់ចិត្តវា វាចង់ដែរទេ ។

00606 ៧ស្រីមាយាកាលី ចូលដេកនឹងប្តី ធ្វើជាដល់ខែ ហើយស្លៀកចងក្បិន ថាមិនទំនេរ ដល់ប្តីវាយជេរ នាំឲ្យមានមោះ ។

00607 ៨ស្រីមាយាមុខរឹង ដឹងជាប្តីនឹង រួមរ័កស្ញាញស្ញុះ ដាស់គេឯងឡើង រកភ័ឯចទះ ព្រោះខឹងពុំនោះ ចង់ចាកស្វាមី ។

00608 ៩ស្រីមាយាបម្រើ ប្តីពុំដែលស្មើ ធ្វើមុខខ្វេវខ្វី ក្សិណស្រស់ក្សិណព្រៀម ក្សិណស្លៀមក្សិណស្តី ព្រោះធុញទ្រាន់ប្តី តូចចិត្តគំនិត ។

00701 ១០ស្រីមាយាខ្ញិចខ្ញង់ ចំណីប្តីចង់ ពុំឲ្យតាមចិត្ត ចង់នោះឲ្យនេះ បន្លះចេញពិត ព្រោះជិនណាយចិត្ត គិតបែកចេញក្រៅ ។

00702 ១១ស្រីមាយាលាយអាស ចង់ឲ្យប្ដីប្រាស ចេញពីលំនៅ នឹងបានចេកលេង គ្នាឯងអ្នកក្រៅ ប្ដីមានបើទៅ អរឯងនឹងពន្លឹក ។

00703 ១២ស្រីមាយាល្បិចល្បែង ប្ដីទៅឆ្ងាយលេង ទាល់ល្ងាចទាល់ព្រឹក សើចលេងតាមចិត្ត គ្មានគិតគ្មាននឹក គ្មានភ្នករពុក អាណិតស្រឡាញ់ ។

00704 ១៣ស្រីមាយាមានោមានះ ប្ដីមកដល់ផ្ទះ ជាទុក្ខត្អាន់ក្អាញ់ កញ្ចប់កញ្ចុំ ក្រមូវកន្ទាញ់ ដ្បិតចិត្តសស្រាញ់ សស្រួលទៅ ផ្សឹន ។

00705 ១៤ស្រីមាយាលែបខាយ ឃើញមុខសហាយ ធ្វើយំឲ្យដឹង អន្ទុយស្ងួតស្ងប់ សញ្ជប់សោកសឹង ធ្វើប្រាប់ដំណឹង ពីខ្ទួនទុក្ខ ទល់ ។

00706 ១៥ស្រីមាយាលាយអាស ឃើញប្រុសមិនខ្លាស ធ្វើរិះរកកល សាកសួរសុំថ្នាំ ផ្ដែផ្ដាំខ្វាយខ្វល់ មោះចង់ជួបយល់ មុខ មិត្រក្នុងក្រៅ ។

00707 ១៦ស្រីមាយាសស្រាញ់ ឃើញមុខសំឡាញ់ ដែលចង់ចិត្តទៅ មើលៗហើយសើច ធ្វើកើចស្ងៀមនៅ បន្តិចមើលទៅ ឲ្យប្រុសស្នេហា ។

00801 ១៧ស្រីមាយាពេកក្ដិត ឃើញប្រុសត្រូវចិត្ត ព្រឺព្រួចចិន្តា ដាក់ភ្នែកមមុយ កន្ទុយនេត្រា លួចមើលរេរា ញញឹមធ្វើ វ្ហៀយ ។

00802 ១៨ស្រីមាយាក្អិចក្អក់ ឃើញប្រុសសំឡក់ កាន់នេះនោះហើយ លើកឡើងថើបថៃ លួចបែរមើលដើយ ថើបទៀតធ្វើ តើយ ញញឹមចោលចេញ ។

00803 ១៩ស្រីមាយាពិតៗ ឃើញប្រុសត្រូវចិត្ត ធ្វើជាម្នាម្នេញ ជិនឆ្នន់ត្រគោះ គឺមោះគិតពេញ ចិត្តចង់លលេញ សេព សុខស្នេហា ។

00804 ២០ស្រីមាយាវេះវេរ ឃើញប្រុសមានគេ នៅផងច្រើនគ្នា ធ្វើជាព្រនើយ កន្ទើយសោះសា តែស្ទាត់មើលវា ស្រដីចច្រាក ។

00805 ២១ស្រីមាយាចេះកិត ឃើញប្រុសធ្វើស្និទ្ធ និយាយសួរសាក នៅផ្ទះនៅវាល ស្រីបស្រាលសើចក្អាក ទើបបន្តិចពាក្យ ទៅប្រុសលលេញ ។

00806 ២២ស្រីមាយាមែនមួន ឃើញប្រុសរត់ពួន កែះក្រចកចេញ កាច់ម្រាមទាំងដប់ ពត់សព្វដៃមិញ ដ្បិតអៀនស្រឡាញ់ នឹងប្រុសអាត្មា ។

00901 ២៣ស្រីមាយាវល្បែង ឃើញប្រុសធ្វើកែង យកជើងព័ន្ធគ្នា ទទោកក្ដេះដី ធ្វើស្ដីម្នាក់វា លួចឈ្លៀងនេត្រា សំឡក់ធ្វើព្រើយ ។

00902 ២៤ស្រីមាយាកិរិយា ឃើញប្រុសធ្វើជា ប្រហើងព្រងើយ ខុនគូសដីលេង តែងងកងើយ លួចសំឡក់ហើយ ញញឹមខុនចុះ ។

00903 ២៥ស្រីមាយាល្បិចល្បែង ឃើញប្រុសធ្វើងង លេងនេះលេងនោះ លេងលាយអំពើ លេងធ្វើម៉ែះម៉ោះ ឲ្យប្រុសកាន់កោះ ត្រេកត្រអរហឫទ័យ ។

00904 ២៦ស្រីមាយាគ្មានពិត ឃើញប្រុសដៃក្បិត សំពត់អាវស្បៃ ស៊ីមចង្កេះផ្ទៀង មើលមៀងប៉ប្រែ សំឡក់វិលវៃ ឈរនៅព្រងើយ ។

00905 ២៧ស្រីមាយាអំពើ ឃើញប្រុសប្រែធ្វើ មិនពត់ខ្លួនជើយ មុខមៀងក្រឡេក ចុងភ្នែករៀយៗ អន្ទុយព្រងើយ ហាក់មិនស្នេហា ។

00906 ២៨ស្រីមាយាយល់ប្រុស ធ្វើអ្វីឲ្យជ្រុះ ជជុះរុះរ៉ា មៀងមើលយល់ជាក់ ប្រែភក្ត្រធ្វើជា រើសរួចហើយវា មើលទៀតញញឹម ។

00907 ២៩ស្រីមាយាឆ្មើងឆ្មិត ឃើញប្រុសស្អាតស្អិត លាបប្រេងប៉ប្រិម ផាត់មុខណាំនួន ក្រមួនមាត់ខឹម ស្លៀកសំពត់ត្រឹម ដណ្ដប់ពាក់ថ្មី ។

01001 ៣០ស្រីមាយាឥតស្រាន្ត ឃើញប្រុសហើយបាន សរពើចំណី អ្វីៗក្ដីណា ហៅគ្នាមកធី ផ្ដោះផ្ដងសំដី ញញឹមបញ្ចើ ។

01002 ៣១ស្រីមាយាស្រីបស្រះ ឃើញប្រុសស្រមះ ស្រមួលអំពើ ដេកដើរឈរអន្ទុយគន់តែធ្វើ អំពើបញ្ចើ បញ្ចូលស្នេហា

។

01003 ៣២ស្រីមាយាលាយចេក ប្រុសបាត់ដើរវេរ៉ុក ធ្វើឆ្កួតលលា ក្សិណសើចក្សិណយំ ក្សិណពុំចរចា ដ្បិតវាប្រាថ្នា ចង់សេពកាមគុណ ។

01004 ៣៣ស្រីមាយាក្រៅក្រិត្យ កំណាញ់ឥតគិត មិនចង់ធ្វើបុណ្យ មិនធ្វើទានសីល ព្រោះខ្ជិលសិប់ស៊ុន ស៊ូចាយផ្តាប់ផ្តុន ប្រុសអស់ពីប្រាណ ។

01005 ៣៤ស្រីមាយាលាមក ចេះតែកុហក វៀចបង្វែនដាន កំភរកំភូត រកស្លូតត្រង់គ្មាន វិលវេះមិនមាន ទប់ទល់សំដី ។

01006 ៣៥ស្រីមាយាញ៉ិកញ៉ក ឃើញប្រុសបញ្ចុក សរពើចំណី ក្មេងស៊ុងងសើច គេចកើចសុំខ្ចី ឲ្យប្រុសភ្ញាប្រិយ ដឹងបុកខ្លួនឯង ។

01007 ៣៦ស្រីមាយាករខ្លួន ឃើញប្រុសបានក្មេង ពនុបប្រឡែង ក្មេងធ្វើម្តេចគាប់ ធ្វើត្រាប់ជាល្បែង ឲ្យប្រុសយល់វែង ចាប់ចិត្តស្រាលស្រើប ។

01101 ៣៧ស្រីមាយាណាស់ណា ឃើញប្រុសធ្វើជា ពក្មេងលេងថើប ថើបឈ្លក់ថើបឈ្លី ថើបញីហើយងើប ធ្វើប្រុសឲ្យស្រើប សម្រើបតណ្ហា ។

01102 ៣៨ស្រីមាយាលេងក្មេង ខនថ្ពាល់ស្តាំឆ្វេង ខ្លួនឯងឲ្យវា ថើបវិញអែនអៀង រលៀងនេត្រា មើលប្រុសរួសរ៉ា សើចហើយវេះវេរ ។

01103 ៣៩ស្រីមាយាផ្សេងៗ ឃើញប្រុសប្រើក្មេង បីឱបចំពេ សើចមើលប្រុសឆាប់ ក្រឡាប់ជាទេ ហុចឲ្យទៅគេ ហើយធ្វើនាំរត់ ។

01104 ៤០ស្រីមាយាឥតខ្មាស ឃើញប្រុសហើយអាស រំសាយសំពត់ ស្ទើរលេចកេរ្តិ៍ខ្មាស ហៅអាសឥតបទ ឲ្យប្រុសក្តួចកត់ ចង់រួមវាសនា ។

01105 សំដែងមាយាស្រី សែសិបអប្រិយ លើសខ្មាតមាត្រា ឲ្យស្រីផងដឹង ដំណឹងពុតវា ម្ញិកម៉្ញក់ណាស់ណា គ្មានការកេរ្តិ៍ប្រាណ ។

01106 ធម្មតាស្រីមាយា ក្តីអ្វីល្អជា គួរធ្វើគួរធ្យាន មិនស្ងៀតចងចិត្ត តែងគិតបំពាន ខូចខុសនោះគ្មាន ព្រយនឿយព្រយស្តី ។

01107 បើប្តីប្រាថ្នា កលកិច្ចស្នេហា ថាឯងនឹងអៀនប្តី ពុំព្រមតាមចិត្ត គំនិតស្វាមី ប្តីអាក់អន់ក្តី មិនព្រឺដល់ស្ពឹច ។

01108 គួរអស់ស្រីជិន គួរចៀសគួរមិន ឲ្យភ្លាត់ភ្លាំងភ្លេច គួរចោលឲ្យបាត់ គួរកាត់គួរគេច គួរវេះគួរវេច កាន់សុចរិតខ្ជាប់ ។

01201 នឹងបានពុំឈ្មោះ ពុំកេរ្តិ៍ពីរោះ ទូទាំងសូរស័ព្ទ បរលោកលោកិយ ហៅស្រីមហាគាប់ លោកទុកជាច្បាប់ អស់ស្រីនានា ។

01202 សោះគិតប្រមាទ ទើបចោលមារយាទ មាយាគ្រប់គ្នា សំដែងចែងចប់ គ្រប់សព្វមាយា សែសិបគណនា តាមព្រះគាថា ។

01203 ទសហិបាទេហិត្ថិយា បទុដ្ឋាទេវិទិតព្វាបិ ភវិស្សន្តេ ស្រីបន្ទិនឯង ហេតុដប់គត់គល់៖

01204 ១នេះដើមបន្ទិន ហេតុតែចង់កិន ឲ្យប្តីកើតដល់ ទោសទុក្ខលំបាក គោកយ៉ាកអំពល់ ដោយចិត្តកំហល់ កំហឹងមោហា ។

01205 ២ស្រីបន្ទិនប្តី ទ្រព្យធនការអ្វី ផងប្តីអាត្មា មិនយកទុកដាក់ ពិភក្តិរក្សា ចោលឲ្យបង់អាសា សោះឥតត្រើយ ។

01206 ៣ស្រីបន្ទិនប្តី ការងារឯស្រី គួរតែធ្វើហើយ ខ្ជិលធ្វើការងារ ដេកលេងកន្ទើយ ពុំគិតធ្វើឡើយ ដើរលេងសប្បាយ ។

01207 ៤ស្រីបន្ទិនប្តី របស់អ្វីៗ ផងប្តីយកចាយ លេងបៀផឹកស្រា ទ្រព្យអន្តរាយ ខាតខូចខាតខ្ចាយ គ្មានបានចំណេញ ។

01208 ៥ស្រីបន្ទិនប្តី ពូកែបុលខ្ចី ជឿគេដូរទិញ ម្ចាស់ទ្រព្យទារតឹង បែរទឹងឲ្យវិញ ប្តីអៀនអន្តមិញ រកសងឲ្យគេ ។

01301 ៦ស្រីបន្ទិនប្តី ចាយវាយឥតបី ប្រមាណរិះរេ បង់ដោយបាត់ដោយ ទម្លោយធ្វេសធ្វេ ទាល់តែដៃទេ តឿនប្តីឲ្យរក ។

01302 ៧ស្រីបន្ទិនប្តី ធ្មើងធ្មៃក្រស្តី ចង់ធំចង់ល្អ ការអ្វីខ្ជីខ្ជា មិនភ្នាមើលយក៍ ធ្វើតែការក្រ ដែលធ្វើក្របាន ។

01303 ៨ស្រីបន្ទិនប្តី ខូចកាឡកិណី ដើរលួចរុករាន គេទាន់វេះចុះ គេចឈ្មោះបំពាន ប្តីវិនខូចប្រាណ រកទ្រព្យឲ្យគេ ។

01304 ៩ស្រីបន្ទិនប្តី ចណ្ណាលគិតអ្វី ច្រើនឈ្មោះជេរគេ គ្មានស្ញើបអ្នកណា ឆ្លេឆ្លាវេះវេរ កើតក្តីមិនទេ ប្តីបង់តែទ្រព្យ ។

01305 ១០ស្រីបន្ទិនប្តី ផាយផិតអប្រិយ ឥតសារឥតស័ព្ទ ចោរអាសគ្មានស្កល់ តែយល់ចុះជាប់ ទ្រព្យប្តីយកគាប់ ចិត្តសហាយ

វា ។

01306 សំដែងបង្ហិន ដប់ហេតុស្រីមិន ចេះទុកទ្រព្យ ចោលខ្ទាត់ចោលខ្ចាយ ចោលរាយនានា ចោលមិនទាំពា មើលទុកឲ្យល្អ ។

01307 បោះទុកតែពាស រាត់រាយទៅផ្កាស គ្មានរៀបរើសរក៍ ទោះឃើញនៅមុខ មិនទុកមិនយក៍ ដើរទៅដើរមក៍ ជាន់លើមិនគិត ។

01308 ជាតិស្រីអប្បលក្ខណ៍ នឹងហិនទទាក់ មិនមានគំនិត ខូចក្ដីខាតក្ដី ឥតបីមានគិត រុះរាយមិនស្សិត យកដៃទៅកាន់ ។

01309 បានតែដើរលេង នឹងគេនឹងឯង ស្រដីរន្ទាន់ អួចចុះអួចឡើង ចរចើងរួសរាន់ មិនមានគ្នេរគ្នាន់ ខាតដោយខូចដោយ ។

01401 អំពើច្នះហោង គួរអស់ស្រីផង ផ្ចង់ចិត្តកុំឲ្យ ចង់ក្ដីសុចរិត ពិនិត្យកុំភ្លោយ កុំមានទុមោយ ទៅកាន់ទុច្ចរិត ។

01402 អត្ថាធិប្បាយ ទ្រង់ត្រាស់បរិយាយ ពីស្រីគំនិត បង្ហិនស្វាមី ដោយក្ដីទុច្ចរិត អំពើដប់ពិត ចែងចប់គាថា ។

01403 អដ្ឋារសហិ ឋានេហិ ឥត្ថីយោគា ខុភិចិត្តអរមានា ស្រីចើកកិរិយា ប្រាំបីដណ្ដប់ ។

01404 ១ នេះដើមស្រីស្រាល ចើកចង់លេងវាល លេងព្រៃមិនស្កប់ ទៅលេងរឿយៗ គ្មានធ្វើយធុញថប់ ទៅថ្ងៃទៅយប់ ទៅយូរមហិមា ។

01405 ២ ស្រីចើកចង់តែ ដើរទៅលេងព្រៃ ចម្ការនានា លេងច្បារឧទ្យាន មិនមានរួញរា ច្រើនដងច្រើនគ្រា ព្រោះចើកឥតត្រើយ ។

01406 ៣ ស្រីចើកចិត្តអ្នក ចើកចង់លេងទូក អុំលេងល្ហាក់ល្ហើយ បន្ទុរសើចសាន មិនមានខ្មាសឡើយ លេងរឿយៗហើយ ព្រោះចើកកន្ទង ។

01407 ៤ ស្រីចើកចោលបុក ចង់ទៅងូតទឹក ងូតម៉ែច្រើនដង ងូតថ្ងៃងូតយប់ ឥតឈប់ឈរហោង ងូតលោតលេងផង ងូតសើចក្អាកក្អាយ ។

01501 ៥ ស្រីចើកអន្ទើក ទៅញាតិអន្ទ្រើក អន្ទុយនិយាយ ថ្ងៃយប់ញយៗ លេងក្ងួយសប្បាយ សើចលេងក្អាកក្អាយ ដោយ

សារចិត្តចើក ។

01502 ៦ស្រីចើកពេកពិត ថ្ងៃយប់នឹកនឹក ដើរលេងអណ្ដើក ផ្ទះឯងមិននៅ ដើរទៅអំបើក ផ្ទះគេទើកៗ ផ្សាចិត្តចង់ក្សាន្ត ។

01503 ៧ស្រីចើកនោះមិញ ចង់ដើររកទិញ គ្រឿងស្អាងខ្លួនបុរាណ ចើកទៅតែផ្សារ ការងាររកខាន ដ្បិតចើកមិនស្រាន្ត មិនស្រាកគណ្ហា ។

01504 ៨ស្រីចើកៗមាំ ទៅឈរបំពាំ មាត់ទ្វាររេររា នៅទ្វាររបង ផ្សៀងផ្អងនេត្រា ច្រើនជងច្រើនគ្រា ដោយចិត្តចើកស្មោះ ។

01505 ៩ស្រីចើកច្រើនចង់ អង្គុយរកគ្រង់ បង្អួចនោះ ប្រហែលជញ្ជាំង បៀតបាំងកៀនកោះ រឿយៗណាស់នោះ ចើកពេញបន្ទុក ។

01506 ១០ស្រីចើកពេកក្រៃ ត្អូញត្អែរឈើថ្ងៃ អង្គុយមិនសុខ ញយៗនោមផ្ទុះ ថាពោះឆ្អែះចុក នៅមិនស្រណុក ផ្សាចើកដាក់ស្តែង ។

01507 ១១ស្រីចើកមិនបាត់ ព្រលប់យប់ស្ងាត់ អង្គុយម្នាក់ឯង លើផ្ទះនៅដី ឥតបីខ្លាចក្រែង ស្រែកស្រលប្រឡែង សូរស័ព្ទព្រាន ។

01601 ១២ស្រីចើកដាក់ស្តែង ចង់ទៅមើលល្បែង មហោស្រពសព្វប្រាន មើលរឿយៗពន់ លើសលន់មិនមាន ការកើតទុក្ខគ្រាសប្រាណ ព្រោះចើកមោហា ។

01602 ១៣ស្រីចើកស្រើបស្រស់ ពុសំឡេងអស់ ប្រសស្ទើរស្ទុះស្ទា គេចៀកផ្សៀងផ្អង សូរសន្ទនាចា រឿយៗគ្រប់គ្រា ដ្បិតចើកសើរើ ។

01603 ១៤ស្រីចើកសស្រញ ចង់ស្តាប់ទំនួញ ទំនុកសរពើ ពាក្យពេចន៍វោហារ ការងារគេធ្វើ ស្ដាប់រឿយលើស ព្រោះចិត្តចើកក្រៃ ។

01604 ១៥ស្រីចើកចោរចិត្ត ទៅចងជាមិត្ត ស្រឡាញ់អាល័យ និងស្រីផ្កាមាស អង្គអាសចង្រៃ ទៅលេងយប់ថ្ងៃ ផ្សាចើកមិនក្សាន្ត ។

01605 ១៦ស្រីចើកក្រឡាស ដើរលេនផ្តេសផ្តាស តាមដោយទីឋាន ប្រឡែងប្រឡូក ច្របូកប្រេះប្រាណ ប្រវាយមិនក្សាន្ត ទះតប់តក់តេច ។

01606 ១៧ស្រីចើកស្តាប់ស្តី និយាយតែពី ល្បែងប្រុសមិនភ្លេច សរសើររូបរាង វាសវាងពាក្យពេចន៍ នឹងប្រុសមិនតិច នឹកៗទៅឯង ។

01607 ១៨ស្រីចើកមុះរឹង ផឹកស្រាស្រវឹង គ្មានខ្មាសគេឯង ផឹករៀយៗនោះ ផឹកឈ្លោះនឹងក្មេង ហានក្លាថ្លាថ្លែង តាមចិត្តចើកចង់ ។

01701 សំដែងចើកគ្រប់ ប្រាំបីដណ្តប់ លក្ខណ៍ស្រីចើកអន្ត កាន់ទុច្ចរិតខ្ជាប់ គ្រឹត្យច្បាប់លះបង់ តាមតែចិត្តចង់ ចំណង់តំនិត ។

01702 ធម្មតាស្រី ចើកចិត្តអប្រិយ តាមក្តីទុច្ចរិត ឃើញប្រុសស្រៀវស្រួច ព្រឺព្រួចក្នុងចិត្ត ចង់តែស្នេហ៍ស្និទ្ធ ព្រោះតណ្ហានាំ ។

01703 ចើកនេះអប្រិយ ត្រូវគប្បីស្រី ទាំងឡាយចងចាំ ថាចើកនេះជួ មោហ៍មួមនាំ ចើកនេះចើកកម្ម ចើកជួរចសោះ ។

01704 ត្រូវស្រីទាំងឡាយ ចោលចើកចេញឆ្ងាយ ពីចិត្តចើកស្មោះ កុំត្រាប់កុំត្រង កុំចងចិត្តចុះ កុំចេះចើកនោះ ចើកនេះជួ ក្រៃ ។

01705 បាលីលោកថា នរស្រីណា ចៀសចើកចង្រៃ កាន់យកសុចរិត ប្រព្រឹត្តប្រពៃ លោកហៅមហាថ្លៃ ក្រៃលែងស្រីផង ។

01706 ទេសនាបរិយាយ ស្រីចើកទាំងឡាយ ជាដានទំនង ប្រាំបីដណ្តប់ ចែងចប់ចើកហោង តាមដោយគន្លង អាចអត្ថគាថ ។

01707 វិសាយហិ ឋានេហិឥត្ថីសាមិកំ អមនាបោ អបិយោ ហោន្តិ វិស្រីអាសទាំង ម្ភៃសេចក្តី÷

01708 ១នេះដើមស្រីអាស វាអាសកាចឆ្នាស ប្រច័ណ្ឌតែប្តី ជាស្រីចាក់ចុច មិនទប់សំដី ផ្ចាញ់ផ្ចាល់ស្វាមី តែសព្វភាសា ។

01709 ២ស្រីអាសចចេស ចេះតែឈ្នានីស គ្មានយល់អ្នកណា របស់ផងគេ ចង់តែប្រាថ្នា មិនបានហើយវា រកកលបន្ទុច ។

01801 ៣ស្រីអាសអប្រិយ ចិត្តធំនឹងប្តី ពុំទទួលគួច បើប្តីធ្ងន់ពាក្យ ប្រែខ្ញាកមាត់ច្បូច ប្រឈ្លោះទទូច គ្មានស្រាកសំដី ។

01802 ៤ស្រីអាសអាស្រូវ ចេះតែចចូវ ដើរស្តីដើមប្តី នឹងអ្នកនោះនេះ ហើយវេះមកស្តី ប្រាប់ញាតិប្រុសស្រី អប្រិយណាស់ណា ។

01803 ៥ស្រីអាសធ្នុរធេះ រាលពីផ្ទះនេះ នាំភ្លើងរួសរ៉ា ទៅឆ្លួលអ្នកផង ឲ្យឆ្លងខ្ទេចផ្សា ពីព្រោះអាត្មា ពុំស្គាល់សុរស័ព្ទ ។

01804 ៦ស្រីអាសឥតស្រាន្ត ប្តីផ្តាំប៉ុន្មាន មិនស្សៀតចង់ស្តាប់ ចច្រេសចច្រាស ច្រឡាសស៊ើរស្ទាប់ គ្មានស្តាប់បង្គាប់ បណ្តាំប្តីពិត ។

01805 ៧ស្រីអាសគ្មានព្រឹម ឃើញប្រុសទំនឹម ទំនុកទៅស្និទ្ធ ឲ្យប្រុសបានដឹង ដំណឹងគំនិត ដែលវាគួចគិត ចង់ចាប់ស្នេហា ។

01806 ៨ស្រីអាសពេកណាស់ ឃើញប្រុសគន្ទាស់ តន្ទេនប្រស្នា ឲ្យប្រុសគិតតាម កើតកាមតណ្ហា ចាប់ចងស្នេហា នឹងវាស្ម័គ្រស្មោះ ។

01807 ៩ស្រីអាសកន្ទាញ់ ឃើញប្រុសកន្តាញ់ មៀនមើលដូច្នោះ ញេចញាក់ចិញ្ចើម ពព្រឹមត្រង់គ្តោះ ឲ្យប្រុសកាន់គោះ កួចកើតមេត្រី ។

01808 ១០ស្រីអាសមិនស៊ើរ ឃើញប្រុសវាដើរ មើលមិចភ្នែកក្ទី ឲ្យប្រុសដឹងអាថ៌ ប្រការសេចក្តី ជួបចូលស្រដី ពាក់ព័ន្ធចំណង់ ។

01809 ១១ស្រីអាសវពិត ប្រុសគេពុំគិត វានាំរារង់ ញាក់មុខញេញធ្មេញ ជន្ទេញឲ្យអន្ត ប្រុសប្រែទឹងចង់ ឈ្នះឈ្នានយកវា ។

01901 ១២ស្រីអាសវលន់ ប្រុសគេមិនគន់ មិនគិតប្រាថ្នា វាស្តោះខាកព្រាត អណ្តាតលៀនហា ឲ្យប្រុសខ្មាសវា ទំចង់ឲ្យបាន ។

01902 ១៣ស្រីអាសច្រឡាម ឃើញប្រុសរត់តាម ប្រឡែងឈ្លានពាន ធ្វើស្និទ្ធសើចសព្វ ទះគប់គក់ច្រាន ឲ្យប្រុសព្រឺព្រាណ ព្រចព្រឺសស្នេហ៍ស្នង ។

01903 ១៤ស្រីអាសចន្រែ ឃើញប្រុសលូកដៃ អន្ទួលពោះខ្លួន ឲ្យប្រុសមើលយល់ គិតដល់ជ្រៅផង នឹកជ្រៅចិត្តចង ចង់

ចាប់នៃបនៅ ។

01904 ១៥ស្រីអាសាវក្រៃ ឃើញប្រុសរើសស្បៃ ដណ្ដប់ថាក្ដៅ បែរបង់កវិញ ទ្រុងមិញនៅក្រៅ ឲ្យប្រុសមើលទៅ ស្រឡាញ់ពុំស្បើយ ។

01905 ១៦ស្រីអាសទាំងសត្វ ឃើញប្រុសដណ្ដប់ ប្រផុតប្រផើយ លេចដោះទ្រលន់ ស្បិតគន់ធ្វើវើយ ឲ្យប្រុសយល់ហើយ ចាប់ចិត្តកាន់កត់ ។

01906 ១៧ស្រីអាសមុខង៉ប់ ឃើញប្រុសឈរឈប់ រំសាយសំពត់ ហើយស្លៀកសំពេះ ស៊ើររទេះខ្ទាងម៉ត់ ឲ្យប្រុសរន្ធត់ ចិត្តចង់រួមរស ។

01907 ១៨ស្រីអាសពព្រើម ឃើញប្រុសរងើម សំពត់ស្រាយអស់ រលាស់រុំសង ឲ្យប្រុសស្រើបស្រស់ ចង់ជួបរួមរស រួមរ័កប្រតិព័ទ្ធ ។

02001 ១៩ស្រីអាសពេញអាស ឃើញប្រុសឥតខ្មាស សើយៗលាត់ៗ សើយភ្លៅនៅតិច រិះលេចអស់ថ្ងាត់ ឲ្យប្រុសសាបមាត់ ចង់ជួបមិនលែង ។

02002 ២០ស្រីអាសបណ្ដាច់ បណ្ដូលអាសផ្ដាច់ ឯកអាសសំញែង ឃើញប្រុសលូកដៃ ឯព្ធខ្មាសឯង ប្រលោមប្រឡែង រាគរសរណើ ។

02003 សំដែងស្រីអាស គ្រប់កេរ្ដិ៍គ្រប់ខ្មាស ម្ភៃសេចក្ដី ឲ្យស្រីផងដឹង ដំណឹងបុកស្រី ថាអាសអប្រិយ ជួជាតិសាមាន្យ ។

02004 អាសនេះពេញពុត មុខរឹងបំផុត មនោមនះឈ្មានពាន ឯប្ដីខ្លួនស្រាប់ ស្បិតផ្ដាប់ធ្វើគ្មាន ចិត្តចង់រួមប្រាណ ចំណង់នឹងប្ដី ។

02005 សំដែងស្រីអាស គួរអាស្រវភាស អស់ទាំងស្ត្រី អាសនេះជួជាតិ លើសខ្មាតអប្រិយ គួរគប្បីស្រី ចាំជាទំនង ។

02006 ចាំហើយពិនិត្យ ក្រែងជួនជាំចិត្ត ចូលចុះគន្លង ជាអាសជូរឆ្នេះ ចូររវេះចេញហោង កុំឲ្យសៅហ្មង អាស្រវអាត្មា ។

02007 កុំចេះអាសទុក យកជាអភិមុខ ជា□លក្ខណា អាសអាក្រក់ក្រៃ ចង្រៃមហិមា គួរស្រីជាៗ ចៀសវាងកុំត្រាប់ ។

02008 អាសនេះមោហ៍បាំង មារបិទចិត្តទាំង ឲ្យគេពុំគាប់ គេគិះដៀលលេង ជាល្បែងសាយសត្វ មិនទុកជាច្បាប់ អស់

កាលដ៏លន់ ។

02009 អំពើចេះហោង គួរអស់ស្រីផង ផ្ទន់ចិត្តឲ្យគន់ អំពើក្រមក្រឹត្យ សុចរិតទុកក្នុង ចិត្តចាំបំរុង គ្រប់ខ្លួនទីទៃ ។

02101 ចូរកុំប្រមាទ ចូរកុំបីឃ្លាត សុចរិតថ្លាថ្លៃ សំដែងស្រីអាស ឥតខ្មាសចង្រៃ ចប់គ្រប់ម្ភៃ ហេតុតាមគាថ់ ។

02102 ទ្វាទសហិ ឋានេហិឥត្ថីសាមិកំ អវជានាតិកាចិត្តំ ស្រីមាក់ងាយទាំង ដប់ពីរកិរិយា ៖

02103 ១ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី ខ្សត់ខ្សោយមហិមា គ្មានសម្បត្តិទ្រព្យ ប្រដាប់ប្រដា ខ្សត់លើសអាត្មា អាត្មាអ្នកមាន ។

02104 ២ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី ពូជពង្សសន្ដាន ទាបតូចថយថោក គ្មានលោករាប់អាន ឯខ្លួនមិញមាន ត្រកូលខ្ពស់ខ្ពង់ ។

02105 ៣ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី អាក្រក់គគ្រង់ គគ្រាតគគ្រិល ក្រនិលក្រនង់ ឯខ្លួនត្រចង់ ល្អស្អាតសោភា ។

02106 ៤ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី កើតព្យាធិរោគា របេងរីងរៃ ល្ហិតល្ហៃគ្រាំគ្រា ខ្លួនមាំមួនជា ធ្វើការឥតអាក់ ។

02107 ៥ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី ចាស់ជរាធ្មេញបាក់ ភ្នែកសសក់ស្កូវ មិនសូវសមស័ក្តិ ខ្លួនឯងហូតថ្នាក់ ក្រមុំជាម្ដង ។

02108 ៦ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី ល្ងង់ខ្លៅកន្លង ឆោតឆៅមមឹង មុខរឹងរូសផង ចចេសដូចផង ខ្លួនឈ្លាសវៃជាង ។

02201 ៧ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី ចង់តែស្អិតស្អាង ដើរលេងចង់ស្រី ស្រដីវាសវាង តឿនទៅប្រផាង ត្រឡប់ជាឈ្លោះ ។

02202 ៨ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី តែងតែទៅឆ្ពោះ លេងបៀលេងប៉ោ ឆោងកេរ្តិ៍កោះ របស់អស់សោះ រំពុកមិនបាន ។

02203 ៩ស្រីមាក់ងាយប្ដី ព្រោះដ្បិតស្វាមី ផឹកស្រាមិនស្រាន្ត មិនស្រាកស្រវឹង ក្សិណទឹងក្សិណក្សាន្ត រំពុកប៉ុន្មាន មិនស្ដាប់ពាក្យគេ ។

02204 ១០ស្រីមាក់ណាយប្តី ព្រោះដ្បិតស្វាមី ខ្ជេញខ្ជិលប៉ោខ្វៃ មិនចេះការងារ ធ្វើការអ្វីទេ ខ្លួនចេះជាងគេ ប្តីមិនចេះប៉ុន ។

02205 ១១ស្រីមាក់ណាយប្តី ព្រោះដ្បិតស្វាមី មិនចេះគិតគន់ មិនរកអម្រែស់ របស់ទ្រព្យធន មកឲ្យប្រពន្ធ ដោយក្តីខ្វះខ្វែន ។

02206 ១២ស្រីមាក់ណាយប្តី ព្រោះដ្បិតស្វាមី ប្រឡូកប្រឡែង មូលមិចចុចចាក់ តាមថ្នាក់នៃល្បែង ឥតមានកោតក្រែង ជេរប្តីអាត្មា ។

02207 បាលីចេះហោង គួរអស់ស្រីផង កាន់តាមពុទ្ធដីកា ប្រងប្រាណប្រយ័ត្ន ប្រងផ្គត់កិរិយា ប្រងចាំចិន្តា ប្រងសុចរិតបាន ។

02208 កុំហ៊ានប្រឈ្លោះ កុំហ៊ានពោកពោះ តំរោះតំរាន ប្រទេចផ្តាសា បំពាបំពាន កុំហួសកុំហ៊ាន ធ្ងន់មាត់ឲ្យប្តី ។

02209 កុំកាន់ទុច្ចរិត កុំមាយាក្រៅក្រឹត្យ កុំបង្ហិនប្តី កុំបើកចិត្តផ្តាស កុំអាសអប្រិយ កុំមាក់ណាយប្តី ហៅក្តីជួជាតិ ។

02301 អំពើទាំងប្រាំ គួរអស់ស្រីចាំ កុំបីប្រមាទ ឲ្យជាក់ក្នុងចិត្ត ប្រព្រឹត្តកុំឃ្លាត យកប្រាំជាអាទិ៍ ទូន្មានអាត្មា ។

02302 ថាប្រាំអំពើ ខូចខុសណាស់តើ គ្មានល្អត្រង់ណា គួរតែកុំត្រាប់ កុំជាប់កិរិយា កុំចងចិន្តា អំពើប្រាំនេះ ។

02303 បើដឹងជាក់ហើយ គួរលះលែងហើយ កុំចង់ឲ្យចេះ កុំត្រាប់ឲ្យធ្លាប់ ទម្លាប់ប្រឡេះ ចោលចេញវាងវេះ ឲ្យអស់ពីប្រាណ ។

02304 អំពើប្រាំនេះ ដ្បិតទេម្តេចចេះ ព្រោះទុច្ចរិតមាន ចោលតែទុច្ចរិត មួយពិតចេញបាន ទាំងប្រាំនោះគ្មាន សោះសូន្យជាម្តង ។

02305 អំពើទុច្ចរិត ជាដើមគំនិត បង្កើតប្រាំហោង ប្រាំបែកដល់រយ បើដោយទំនង បែកច្រើនកន្ទង ពណ៌នាពុំបាន ។

02306 មានតែសុចរិត តាំងជាគំនិត ជាត្រប្រធាន ទើបកាចទុច្ចរិត គំនិតប្រាំគ្មាន អ្វីៗមិនមាន កាចប្រាំនេះឡើយ ។

02307 ចូរអស់ស្រីផង ចាំអត្ថគន្លង ទូន្មាននេះហើយ កុំឲ្យភ្លាំងភ្លេច កុំគេចគោះតើយ ចូរគិតកុំស្បើយ ត្រង់ក្តីសុចរិត ។

02308 ព្រះធម៌ទេសនា អំពីលក្ខណា ស្រីជាទុច្ចរិត អំពើទាំងប្រាំ ផ្លូវរយហេតុពិត អំពើសុចរិត ប្រាំបីប្រការ ។

02309 ផ្ទុំគ្នាទាំងទ្វី ត្រូវមួយរយប្រាំបី លក្ខណៈតាមអាថ៌ អត្ថព្រះបាលី គម្ពីរធម៌ធារ អត្ថព្រះអាចារ្យ ចែងចប់បរិយាយ ។

02401 នេះនឹងតែងត ដំណើរដំណា ឲ្យប្រុសទាំងឡាយ ដឹងដល់ចិត្តស្រី តាមក្តីអធិប្បាយ អាចារ្យចែងចាយ ជាបទបាថៈ ។

02402 តាមពុទ្ធដីកា ទ្រង់ត្រាស់ទេសនា ដើមព្រះគាថៈ កតមេហិត្តិហិឥធ អនុរុទ្ធ មាតុគ្គាមា ។

02403 ប្រែអត្ថដើមបទ ថាហៃអនុរុទ្ធ អស់ស្រីនានា សឹងមានចិត្តចាំ រៀនរាំចិន្តា ទាំងបីពេលា គ្រប់ស្រីដូច្នេះ៖

02404 ១ពីព្រឹកលុះត្រង់ ចិត្តស្រីច្រើនចង់ ឆ្មេញឆ្មិលលោះលេះ គន់គិតកំណាញ់ ក្នាន់ក្នាញ់នោះនេះ រសោះរសេះ ហួន ហឫទយា ។

02405 ២ពីត្រង់លុះយប់ ច្រើនចង់សេពសព្វ សរពើអ្វីជា សម្រេចសម្រួល ស្រស់ស្រួលនេត្រា ពុំនោះនឹកឈ្នានីសដល់អ្នក ផង ។

02406 ៣ពីយប់លុះព្រឹក ច្រើនតែគិតនឹក ស្រណោះជាមួន ពុំនោះច្រើនតែ ចង់ស្នេហ៍ស្និទ្ធស្នន រួមរសរាគផង ចំណង់តណ្ហា ។

02407 ដំណើរនៃចិត្ត ស្រីច្រើនប្រព្រឹត្ត តាមដោយពេលា ទាំងបីប្រាកដ ដូចបទគាថា ឲ្យប្រុសនានា ដឹងចិត្តនៃស្រី ។

02408 នេះនឹងពណ៌នា តាមព្រះគាថា អាថ៌អត្ថសេចក្តី ព្រះពុទ្ធទេសនា មាននាបាលី អង្គុត្តនិកាយកបអត្ថៈ៖

02501 ឥត្ថិពុទ្ធំ បុរិសរូបំ ហសិតេន ភណិតគីតា រោណ្ណកប្ប វិនភន្ត ផស្សោឥត្ថិ ។

02502 មួយសោតលោកថា ព្រះពុទ្ធទេសនា ថាប្រុសនឹងស្រី រមែងស្នេហា ចងជាមេត្រី ដោយក្តីប្រាំបី ប្រការប្រាកដ៖

02503 ១មួយគឺចងចិត្ត ចង់នឹងចរិត ធ្វើជាស្រគត់ ផ្ចិតផ្ចង់បុករាប សុភាពបានបទ ស្អិតស្អាងហ្មត់ចត់ ខ្ទប្រាណអាត្មា ។

02504 ២ចងមួយទៀតទៀង នឹងបែរមើលមៀង ប្រទះមុខគ្នា ញញែមញញឹម ប៉ប្រឹមភក្រ្តា ស្រស់ស្រួលសោភា សើចសម គួរកោះ ។

02505 ៣ចងមួយនឹងក្តី និយាយស្រដី ទន់ទៀងស្ងានស្ងោះ សំឡបសំឡុត លំអួតចំពោះ ពាក្យពោលពីរោះ រាយរាប់សំដី ។

02506 ៤ចងមួយទៀតទៀង នឹងសូរច្រេចច្រៀង ឥតភ័ន្តពាក្យពីរោះរាយទំនុក ដាក់ទុកសេចក្តី ផ្អែមផ្អុកមេត្រី ផ្សព្វផ្សាយ សន្តាន ។

02507 ៥ចងមួយនោះមិញ នឹងក្តីទន្ទេញ ទន្ទឹងមិនស្រាន្ត មិនស្រាកចិត្តនឹក រលឹកចង់បាន ជាទុក្ខប្រះប្រាណ យំសោករៀបរាប់

។

02601 ៦ចន់មួយនោះនឹង ប្រឹងប្រាណប្រែប្រឹង ធ្វើបុកគួរគាប់ រៀបចំរូបរាង សព៌ាង្គចំណាប់ ហ៊ុំហាស្វាហាប់ លើសជន
នានា ។

02602 ៧ចន់មួយនោះទៀត នឹងក្ដីឆ្លាស់ឆ្លៀត អរឲ្យទ្រព្យា មានផ្កាជាអាទិ៍ ល្អស្អាតសោភា ដែលខ្ញុំនិម្មា កាច់មកពីព្រៃ
។

02603 ៨ចន់មួយទៀតនោះ នឹងក្ដីស្ម័គ្រស្មោះ ផ្ដេកផ្ដិតមូលមេត្រី ត្រេកមនោរម្យ ផ្សាផ្សុំហឫទ័យ សម្លូតភិរម្យម័យ ត្រូវ
តាមបំណង ។

02604 ក្ដីចន់សង្សារ ប្រាំបីប្រការ គ្រប់ប្រសើរផង តែងតែចងចាប់ ចិត្តភ្ជាប់ស្នេហ៍ស្និទ្ធ ដូចបាលីចង ជាធម៌ទេសនា ។

02605 មួយសោតព្រះពុទ្ធ ទេសនាចំហុត ថាភរិយា មានប្រាំពីរស្មោះ ប្អូននោះចិត្តជា បីនោះមោហា ចិត្តខូចណាយដាយ
:

02606 ១ឯប្រពន្ធជា ឯកស្មោះមាតាភរិយាដូចម្ដាយ ឈឺឆ្អាលកូនខ្លួន វែងស្ងួនមិនណាយ មិននឹករសាយ ចិត្តចាំអាណិត ។

02607 កូនទុក្ខទោសមេត្ត ខ្វល់ក្រៃច្រើនគិត ទំនុកខូចចិត្ត ព្រាត់ប្រាសយូរល័ង់ ពុំបង់បែកចិត្ត គង់ចាំចិត្តគិត ឈឺឆ្អាលកូន
ស្មោះ ។

02608 ប្រពន្ធណាគាប់ ឈឺឆ្អាលប្ដីខ្ជាប់ ចិត្តចាំកាន់កោះ ដូចម្ដាយស្រឡាញ់ កូនពេញពីពោះ ហៅប្រពន្ធនោះ ថ្លៃឥតផ្ទឹមដល់
។

02701 ២ប្រពន្ធជាទី ឈ្មោះហៅទាសីភរិយាដូចកល់ ខ្ញុំនឹងម្ចាស់ ប្រើណាស់ខ្វាយខ្វល់ អាចអត់ទប់ទល់ ទម្ងន់បម្រើ ។

02702 មិនមានទំនេរ ទោះម្ចាស់វាយជេរ អត់ធ្មន់សពើ តាមតែបង្គាប់ ប្រញាប់ចង់ធ្វើ ចិត្តពុំសើរើ ចៀសវាងក្រោធា
។

02703 ប្រពន្ធណាអត់ ធ្មនអន្ទអំណត់ ខ្លាចប្ដីអាត្មា ដូចខ្ញុំនឹងម្ចាស់ ខ្លាចណាស់ធានា ប្រពន្ធនោះជា ប្រសើរសុខសូន្យ ។

02704 ៣ប្រពន្ធជាត្រី ឈ្មោះភគិនី ភរិយាដូចប្អូន ស្រឡាញ់បងពិត លំអិតលំអួន ទទួលដំបូន្មានមាត់ពាក្យបង ។

02705 ផ្តាច់ផ្តួលតែមួយ នឹងចងជាត្រយ ចិត្តចាំបំណង ពំនាក់ពំនឹង ពាក់ពឹងប៉ុនប៉ង តែនឹងអន្តបង់ ឥតម៉ែទីទៃ ។

02706 ប្រពន្ធណាចូល នឹងប្តីមួយមូល ចិត្តជាប់អាល័យ ដូចប្អូននឹងបង ចាំចងអាស្រ័យ ប្រពន្ធនោះថ្លៃ មធ្យមពេកពិត ។

02707 ៤ប្រពន្ធចត្ថា ឈ្មោះហៅសខាភរិយាដូចមិត្ត សំឡាញ់ស្រឡាញ់ អស់អញពេកពិត ស្និទ្ធនស្និទ្ធចិត្ត ស្ម័គ្រស្មោះចិន្តា ។

02708 បើមិត្តទៅបាត់ ស្ងប់ស្ងួតមុខមាត់ ទុក្ខទន់ទយា ឃើញមុខមកបាន ចិត្តក្សាន្តសោះសា ស្រស់ស្រួលភក្ត្រា និរទុក្ខសោកសៅ ។

02709 ប្រពន្ធណាចិត្ត ស្រឡាញ់ប្តីពិត គ្មានក្នុងគ្មានក្រៅ ដូចមិត្តនឹងមិត្ត ចងចិត្តជាប់នៅ ប្រពន្ធនោះហៅ ឧត្តមក្រមាន ។

02801 សំដែងភរិយា ទាំងបួនសឹងជា គ្រស្រីធ្វើបាន បើស្រីណាគិត ផ្ចង់ចិត្តសន្តាន ស្រឡាញ់ប្តីប្រាណ ដូចធម៌ទេសនា ។

02802 លោកថាស្រីនោះ ក្នុងកេរ្តិ៍ពីរោះ ទូទៅនានា បើអស់ជីវិត ទៅឋិតសួគ៌ា ចៀសចាកចតុរាបាយបាបទុក្ខភ័យ ។

02803 ៥ប្រពន្ធពុំជា ឈ្មោះវធកាភរិយាដូចនៃ សត្រូវចាំចង ទោសផងសព្វថ្ងៃ ប្រពន្ធចង្រៃ ប្តីមានតែទុក្ខ ។

02804 បើប្តីខុសចិត្ត វាគ្មានអាណិត ខេរខឹងជាអុក ចាំចងទោសប្តី ស្រដីកិចកុក ឲ្យមាត់ឲ្យមុខ វេះវាងវ្ហាះវ្ហើយ ។

02805 សុខទុក្ខសាំទាំ វាមើលបំណាំ នៅស្ងៀមព្រងើយ ពុំជួយទុក្ខភ័យ ដោះដៃកន្តើយ ស្លាប់ដោយរស់ដោយ គ្មានចិត្តមេត្រី ។

02806 ៦ចោរីភរិយា ប្រពន្ធពុំជា លបលួចទ្រព្យប្តី គ្មានចិត្តករុណា មេត្តាប្រណី របស់ទ្រព្យអ្វី លក់ចាយអស់ធួន ។

02807 ៧អយ្យាភរិយា ប្រពន្ធពុំជា ដំកើងតែខ្លួន ចេះតែប្រើប្តី ឥតបីមានសួន ធ្វើបុកណាំនួន ទុកប្តីដូចខ្ញុំ ។

02808 ប្រពន្ធទាំងបី ធ្លាក់ទៅអវិចី រងទុក្ខដំណំ ក្នុងខ្ទះភ្លើងក្តៅ យូរនៅក្រៀមក្រំ ព្រោះចិត្តខុសធំ ជាន់ប្តីអាត្មា ។

02809 ឯប្រពន្ធបួន មុននោះគួរសួន យកជាភរិយា នឹងកើតរបស់ កេរ្តិ៍យសសក្កា ថ្កើនពូជពង្សា សោយសុខថេរបិត ។

02810 សំដែងបរិយាយ ភរិយាទាំងឡាយ ប្រាំពីរចរិត ទាំងជូទាំងជា ពណ៌នាពោលពិត ចែងចប់ពិនិត្យ តាមអត្ថគាថា ។

02901 កតមេហិ បញ្ចគតិហិសាមិកា ភរិយាសន្តហាសម្មា ប្រែតាមអត្ថាធិប្បាយបាលី ។

02902 ថាប្រុសឯណា នឹងមានភរិយា លោកឲ្យចេះក្តី ទាំងប្រាំចំពោះ សង្គ្រោះចិត្តស្រី ប្រពន្ធប្រក្រតី ដូចធម៌សំដែង ។

02903 បើប្តីឯណា ពុំកាន់កិរិយា ទាំងប្រាំនេះឯង ហៅប្តីទុជ៌ន ជួលនៃក្រៃលែង ចេះតែកំហែង ចិត្តប្រពន្ធពិត ។

02904 បើប្តីកាន់ច្បាប់ ទាំងប្រាំនេះខ្ជាប់ ហៅប្តីសុចរិត ប្រុសនៃភរិយា ដោយនាក្រមក្រឹត្យ ប្រសើរពេកពិត ឥតអ្វីផ្ទឹមឡើយ ។

02905 អស់ប្រុសទាំងឡាយ ចូរចាំអធិប្បាយ ច្បាប់នេះជាត្រើយ ទុកគ្រប់ប្រុសប្រាណ កុំមានកន្តើយ មានប្រពន្ធហើយ ជាសុខសម្រាន្ត :

02906 ១មួយគឺឲ្យប្តី ហៅប្រើស្រដី នឹងប្រពន្ធមាន ពាក្យទន់ពីរោះ ស្មើស្មោះដោយក្សាន្ត សរសើររាប់អាន តាមសព្ទវាចា ។

02907 ២មួយគឺប្រពន្ធ ខុសឆ្គងស្រាលធ្ងន់ កុំជេរផ្តាសា ទាត់ធាក់ដៀលដំ ដូចខ្ញុំអាត្មា កុំស្តីដើមថា ឲ្យព្រួសាយសព្ទ ។

02908 ៣មួយគឺបានធន ប្រគល់ប្រពន្ធ ទុកដាក់រណ្តាប់ ទាំងគ្រឿងអាហារ ជាការស្រេចផ្តាប់ រៀបចំសម្រាប់ ថែទាំរក្សា ។

03001 ៤មួយគឺកុំផ្ចង់ កុំខំតែបង្កើតកូនហើយថា ប្រពន្ធសុខចិត្ត ឲ្យគិតប្រាជ្ញា រួសរកទ្រព្យា សម្រាប់ឲ្យផង ។

03002 ៥មួយគឺឲ្យចាប់ ស្រឡាញ់ឲ្យខ្ជាប់ កុំជិនណាយហោង បើមានប្រពន្ធ ទៀតកុំប៉ុនប៉ង ស្រឡាញ់ស្នេហ៍ស្នង ឲ្យស្មើមុនឡើយ ។

03003 សំដែងសេចក្តី គ្រប់ប្រាំវិធី ចែងចប់ស្រេចហើយ ឲ្យអស់ប្រុសផង ចាំចងជាត្រើយ ផ្ចង់កុំកន្តើយ ចោលច្បាប់បុរាណ ។

03004 បើប្រុសឯណា ពុំផ្ចង់ចិន្តា ដូចធម៌ទូន្មាន នៅនឹងភរិយា គ្មានជាសុខសាន្ត ហិនហោចធនធាន ទាស់ទែងលែងគ្នា ។

03005 ឯវិស័យចិត្ត អស់ស្រីផងពិត មានប្តីប្រាជ្ញា អំពើទាំងប្រាំ នេះចាំចិន្តា គ្រប់ចិត្តភរិយា នៅនាលោកិយ ។

03006 បើខ្វះអំពើ ណាមួយហើយតើ ប្រពន្ធថាប្តី ចិត្តពុំត្រូវត្រង់ ពុំគង់មេត្រី តូចចិត្តស្វាមី អាក់អន់ពុំស្មោះ ។

03007 លោកឲ្យប្រុសផង គន់គិតសួនគ្រង ផ្ចង់ចិត្តសង្គ្រោះ ប្រពន្ធឲ្យពិត ដោយក្រឹត្យប្រាំនោះ ប្រពន្ធក៏ស្មោះ ចិត្តចូលមូលឯង ។

03008 កុំគិតតែយក ប្រពន្ធបានមក គ្រាន់ឱបប្រឡែង បង្កើតតែកូន សោះសូន្យធនធេង លោកឲ្យគិតក្រែង ដំនៀលនិន្ទា ។

03009 ធម្មតាជាប្តី បានទ្រព្យធនអ្វី ឬយសសក្តា តែនៅសុខសិន ទីពឹងផងគ្នា ព្រោះដ្បិតភរិយា កាន់ក្តីសុចរិត ។

03010 អំពើច្នេះហោង ឲ្យអស់ប្រុសផង ចងចាំក្នុងចិត្ត តាមធម៌ទូន្មាន គ្រប់ប្រាណប្រុសពិត ទុកជាក្រមក្រឹត្យ ច្បាប់ច្បាស់តទៅ ។

03101 អន្តអញរចនា សេចក្តីកាព្យា តាមច្បាប់ទុកនៅ ក្នុងព្រះបាលី សេចក្តីជាលជ្រៅ ពុំហ៊ានសៅដៅ លើកលេងងាយដាយ ។

03102 ឧស្សាហ៍ទំប្រង ប្រែរករើសក្នុង គម្ពីរនិកាយ អដ្ឋកថា ដីកាបរិយាយ និបាតទាំងឡាយ មកផ្សំស្រដី ។

03103 ជាច្បាប់ទុកត់ ដំណឹងដំណា ដំណើរស្ត្រី ឲ្យជាក់ប្រាកដ ដោយបទបាលី គ្រាន់អស់ប្រុសស្រី រើសរៀនរកផ្លូវ ។

03104 ច្បាប់នេះប្រសើរ ដំណឹងដំណើរ ទំនងនេះកូវ ជាច្បាប់ប្រាកដ ដោយបទត្រឹមត្រូវ គួរយើងឥឡូវ ប្រតិបត្តិរក្សា ។

03105 គួររៀនឲ្យស្ទាត់ ឲ្យចាំរត់មាត់ ជាក់ក្នុងចិន្តា គ្រាន់នឹងប្រិតប្រៀន បង្រៀនអាគ្នា តាមដោយគាថា នេះឯងតទៅ ។

03106 ចែងចប់អភិប្រាយ ដោយអត្ថបរិយាយ សូរចៃថ្ងៃសៅរ៍ ប្រាំបីរោចឯ នាខែមាឃនៅ ឆ្នាំរកាត្រូវ នព្វស័កស្រេចហោង ។

03107 ចប់

( KWIC INDEX )

01404 លេនព្រៃមិនស្កប់ ទៅលេនរឿយ ៗ គ្មានទៀយធុញថប់ ទៅថ្ងៃទៅយប់ ទៅយូរមហិមា ។ ២ស្រីចើកចង់តែ

00803 ញីមទោលចេញ ។ ១៩ស្រីមាយាពិត ៗ ឃើញប្រុសត្រូវចិត្ត ធ្វើជាម្នោម្នេញ ជិនឆ្នន់ត្រូតោះ គីមោះគិតពេញ ចិ

01103 ហឹយវេះវេរ ។ ៣៩ស្រីមាយាផ្សេង ៗ ឃើញប្រុសប្រើក្មេង បិទបប់ពេ សើចមើលប្រុសឆាប់ ក្រឡាប់ជាទេ ហុច

02007 អាក្រក់ក្រៃ ចព្រៃមហិមា គួរស្រីជា ៗ ចៀសវ៉ាងកុំត្រាប់ ។ អាសនេះមោហ៍ប៉ាំង ម៉ារបិទចិត្តខ្ទាំង ឲ្យគេពុំគាប់

01207 ងសប្បាយ ។ ៩ស្រីបង្អិទប្តី របស់អ្វី ៗ ផងប្តីយកចាយ លេងបៀផឹកស្រា ទ្រព្យាអន្តរាយ ខាតខូចខាតខ្វាយ គ្មាន

01502 មិននៅ ដើរទៅអំបើក ផ្ទះគេទ្វើក ៗ ផ្សាចិត្តចង់ក្សាន្ត ។ ៧ស្រីចើកនោះមិញ ចង់ដើររកទិញ គ្រឿងស្អានខ្នុ

01501 តិអគ្រើក អន្តយនិយាយ ថ្ងៃយប់ញយ ៗ លេងភ្ជួយសប្បាយ សើចលេងក្អាកក្អាយ ដោយសារចិត្តចើក ។ ៦ស្រីចើ

02001 ឃើញប្រុសឥតខ្មាស សើយៗលាត់ ៗ សើយភ្លៅនៅតិច រិះលេចអស់ថ្ងាត់ ឲ្យប្រុសសាបមាត់ ចង់ជួបមិនលែង

00905 មុខមៀងក្រឡេក ចុងភ្នែករឿយ ៗ អន្តយព្រើយ ហាក់មិនស្នេហា ។ ២៨ស្រីម៉ាយាយល់ប្រុស ធ្វើអ្វីឲ្យជ្រះ

01907 ងើម សំពត់ស្រាយអស់ រលាស់រុស ៗ ឲ្យប្រុសស្រើបស្រស់ ចង់ជួបរួមរស រួមរ័កប្រតិព័ទ្ធ ។ ១៩ស្រីអាសពេញ

02202 ទៅឆ្ពោះ លេងបៀលេងប៉ោ ឆោ ៗ គេក្តីកោះ របស់អស់សោះ រំពុកមិនបាន ។ ៩ស្រីមាក់ងាយប្តី ព្រោះដ្សិត

01001 ឃើញប្រុសហើយបាន សរពើចំណី អ្វី ៗ ក្តីណា ហៅគ្នាមកឆី ផ្ទះផ្តងសំដី ញញឹមបញ្ចើ ។ ៣១ស្រីមាយាស្រើបស្រ

01904 ង ចង់ចាប់នៃបនៅ ។ ១៥ស្រីអាស ៗ ក្រៃ ឃើញប្រុសរើសស្បៃ ដណ្តប់ថាក្តៅ បែរបង់កវិញ ទ្រូងមិញនៅព្រ

01602 ចៀកផ្អៀងផ្អង សូរសព្ទវាចា រឿយ ៗ គ្រប់គ្រា ដ្សិតចើកសើរើ ។ ១៨ស្រីចើកសស្រេញ ចង់ស្តាប់ទំនួញ ទំនុកសរ

01505 ញ្ញាំង បៀតប៉ាំងកៀនកោះ រឿយ ៗ ណាស់នោះ ចើកពេញបន្ទុក ។ ១០ស្រីចើកកើកក្រៃ ក្អួញក្អួរឈើថ្ងៃ អន្ត

00405 ចេះគន់បែបបទ តាមតែប្តីពត់ ម្តេច ៗ តាមបាន ។ មិនមានប្រកែក មិនមានជជែក ថាធ្វើមិនបាន ទោះអៀនអន់

01606 វ៉ាងពាក្យពេចន៍ នឹងប្រុសមិនតិច នឹក ៗ ទៅឯង ។ ១៨ស្រីចើកមុខរឹង ផឹកស្រាស្រវឹង គ្មានខ្មាសគេឯង ផឹករឿយ

01506 ក្អួញក្អួរឈើថ្ងៃ អន្តយ៉មិនសុខ ញយ ៗ នោមជុះ ថាពោះឆ្អុះចុក នៅមិនស្រណុក ផ្សាចើកជាក់ស្តែង ។ ១១ស្រី

01607 ាស្រវឹង គ្មានខ្មាសគេឯង ផឹករឿយ ៗ នោះ ផឹកឈ្លោះនឹងក្មេង ហានកាចថ្លៃង តាមចិត្តចើកចង់ ។ សំដែងចើកព្រ

01601 ង មហាស្រពសព្វឋាន មើលរឿយ ៗ ពន់ លើសលន់មិនមាន ការគេក្តីខ្មាសប្រាណ ព្រោះចើកមោហា ។ ១៣ព្រ

01809 សជី ពាក់ព័ន្ធចំណង់ ។ ១១ស្រីអាស ១ពិត ប្រុសគេពុំគិត វានាំរារង់ ញាក់មុខញញឹមញញេញ ជន្លេញឲ្យអន្ត ប្រុសៃ
00406 សន្តក់ចិត្តប្រាណ តាមចិត្តប្តីធ្យាន មេត្ច ១មិនថា ។ ច្បាប់នេះគួរស្រី នៅនាលោកិយ ផ្ចង់ចិត្តឧស្សាហ៍ កាន់គ្តីសុចរិត
02306 ន ទើបកាចទុច្ចរិត គំនិតប្រាំគ្មាន អ្វី ១មិនមាន កាចប្រាំនេះឡើយ ។ ចូរអស់ស្រីផង ចាំអត្ថគន្លង ទូន្មាននេះហើ
01504 សាន្ត មិនស្រាកតណ្ហា ។ ៨ស្រីចោក ១មាំ ទៅឈរបំពាំ មាត់ទ្វាររេរា នៅទ្វាររបង ផ្សៀងផ្លូវនេត្រា ច្រើនដ
01901 ង ឈ្នះឈ្នានយកវា ។ ១២ស្រីអាស ១លន់ ប្រុសគេមិនគន់ មិនគិតប្រាថ្នា វាស្ទោះទាកព្រាត អណ្តាតលៀនហា
02001 ញអាស ឃើញប្រុសឥតខ្មាស សើយ ១លាត់ង សើយក្លៅនៅតិច រិះលេចអស់ថ្នាក់ ឲ្យប្រុសសាបមាត់ ចង់ជួបមិ
00901 ញ ទីងប្រុសអាត្មា ។ ២៣ស្រីមាយា ១ល្បែង ឃើញប្រុសធ្វើកែង យកជើងព័ន្ធគ្នា ទទោកផ្អឹះដី ធ្វើស្ត្រីម្នាក់វា ល្អ
01406 ាន មិនម៉ាន់ខ្មាសឡើយ លេងរឿយ ១ហើយ ព្រោះចោកកន្លង ។ ៩ស្រីចោកចោលចុក ចង់ទៅងូតទឹក ងូតម៉ៃច្រើ
00707 មុខសំឡាញ់ ដែលចង់ចិត្តទៅ មើល ១ហើយសើច ធ្វើកែចស្ងៀមនៅ បង្កិចមើលទៅ ឲ្យប្រុសស្នេហា ។ ១៧ស្រ
